
ជាតិខ្មែរ ~ ចិត្តខ្មែរ
១- ជាតិខ្មែរមានខ្មាំងតាំងកំចាត់
ជាតិខ្មែរវិបត្តិក្នុងនគរ
ជាតិខ្មែរមិនស្ងៀមមិនឈប់ឈរ
ជាតិខ្មែរធ្លាប់ល្អមិនឱ្យអាប់ ។
ជាតិខ្មែរបែរមុខទល់សត្រូវ
ជាតិខ្មែរឥឡូវត្រូវចាក់កាប់
ជាតិខ្មែរផ្តួលខ្មាំងបានយ៉ាងឆាប់
សត្រូវដេកស្លាប់ក្នុងព្រឹក្សព្រៃ ។
ជាតិខ្មែរពូកែចិត្តក្លាហាន
ជាតិខ្មែរតាមដានដេញប្រល័យ
ជាតិខ្មែរកំចាត់ជាតិសាសន៍សៃឃ៍
ចោរជាតិលួចដីមិនឱ្យសល់ ។
២- ចិត្តខ្មែរតស៊ូមិនរុញរា
ចិត្តខ្មែរគ្រប់គ្នាឥតអំពល់
ចិត្តខ្មែរស្អប់ណាស់ពូជអកុសល
ចិត្តខ្មែរតបទល់លុះជោគជ័យ ។
៣- ជាតិខ្មែរ-ចិត្តខ្មែរធ្លាប់រឹងប៉ឹង
ជាតិខ្មែរ ធ្លាប់ដឹងច្បាប់វិន័យ
ធ្លាប់រីកចំរើនគ្រប់វិស័យ
ធ្លាប់ឈ្នះគូដៃជាសត្រូវ ។
៤- ជាតិខ្មែរ-ចិត្តខ្មែរស៊ូដិរាប
លុះត្រាសន្តិភាពអស់អាស្រូវ
តស៊ូដិរាបចប់គោលដៅ
ឃើញផ្លូវសុខសាន្តសប្បាយអើយ ។